# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Apr-2013, 11:59
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សេចក្ដីជំទាស់របស់លោក ខៀវ សំផន
## នៅនឹងការដាក់បញ្ចូលក្នុងកិច្ចពិភាក្សានូវសក្ខីកម្មជាលាយលក្ខណ៍អក្សរមួយចំនួនដែលស្នើ ដោយសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ួច ស្រីផាត់

លោក Pierre TOUCHE

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) ឲ្យប្រកាសទទួលយកឯកសារសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សីដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី១ ទុកជាឯកសារភស្តុតាងក្នុងសំណុំរឿង (“សំណើសុំទីមួយ”)[1]។

២. សំណើសុំទីមួយនេះភ្ជាប់ដោយឧបសម្ព័ន្ធចំនួន ៥ ក្នុងនោះ ឧបសម្ព័ន្ធពីរដំបូងគឺជាឯកសារដកស្រង់កំណត់ហេតុស្តាប់យកចម្លើយសាក្សីធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចំនួន ១៧៧ កំណត់ហេតុ ហើយដែលមានលក្ខណៈជាប់ពាក់ព័ន្ធទៅនឹងដំណាក់កាលទី១ នៃការជម្លៀសប្រជាជនដូចដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[2]។ ឧបសម្ព័ន្ធទី ៣ គឺជាឯកសារដែលមានលក្ខណៈជាការសង្ខេបអង្គហេតុក្រោមទម្រង់ជាតារាងសក្ខីកម្មទាំងអស់ ដែលមាននៅក្នុងឧបសម្ព័ន្ធទាំងពីរដំបូង[3]។ ឧបសម្ព័ន្ធទី ៤ គឺជាឯកសារសម្រង់ឈ្មោះរបស់សាក្សីទាំងអស់ ដោយរៀបតាមលំដាប់អក្ខរាវិរុទ្ធ[4]។ ហើយជាចុងក្រោយ ឧបសម្ព័ន្ធ ៥ គឺជាឯកសារផែនទីចំនួនពីរ ដែលបង្ហាញអំពីទីតាំងដែលប្រជាជនជម្លៀសបានទៅដល់[5]។

៣. នៅថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើសុំទីពីរដែលស្នើឲ្យអង្គជំនុំជម្រះដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សា នូវសក្ខីកម្មទាំងឡាយរបស់សាក្សីដែលជាប់ពាក់ព័ន្ធនឹង

---

[1] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅដំណាក់កាលទី ១ ឯកសារ **E208** ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២។

[2] ដូចយោងខាងលើ, ឯកសារ **E208.1** និងឯកសារ **E208.2**។

[3] ដូចយោងខាងលើ, ឯកសារ **E208.3**។

[4] ដូចយោងខាងលើ, ឯកសារ **E208.4**។

[5] ដូចយោងខាងលើ, ឯកសារ **E208.5**។

ដំណាក់កាលទី២នៃការជម្លៀសប្រជាជន (“សំណើសុំទីពីរ”)[6]។ សំណើសុំទីពីរនេះមានភ្ជាប់ដោយឧបសម្ព័ន្ធចំនួន ៤។ ឧបសម្ព័ន្ធទី ១ គឺជាឯកសារដកស្រង់សក្ខីកម្មដែលបានមកពីកំណត់ហេតុស្តាប់យកចម្លើយសាក្សីធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតចំនួន ៥១ សក្ខីកម្ម[7]។ ឧបសម្ព័ន្ធទី ២ គឺជាឯកសារសង្ខេបអង្គហេតុក្រោមទម្រង់ជាតារាងឯកសារដកស្រង់សក្ខីកម្មទាំងអស់ ដែលមាននៅក្នុងឧបសម្ព័ន្ធ ១។ ឧបសម្ព័ន្ធទី ៣ គឺជាឯកសារសម្រង់ឈ្មោះសាក្សីទាំងអស់ដោយរៀបតាមលំដាប់អក្ខរាវិរុទ្ធ ហើយឧបសម្ព័ន្ធទី ៤ គឺជាឯកសារផែនទីដែលបង្ហាញទីតាំងជម្លៀសចំនួន ៥៨ កន្លែងខុសៗគ្នា រៀបរាប់ដោយសាក្សីចំនួន ៤០ រូប។

៤. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើសុំទីបី ដែលភ្ជាប់ដោយឧបសម្ព័ន្ធចំនួន ១៦[8]។

៥. ឧបសម្ព័ន្ធ ១ និង ២ គឺជាឯកសារបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ (រួមទាំងពាក្យបណ្តឹងផងដែរ) និងឯកសារប្រតិចារឹកនៃការផ្តល់សក្ខីកម្មក្នុងអំឡុងសវនាការលើសំណុំរឿង ០០១។ ពីឧបសម្ព័ន្ធ ៣ ដល់ ១៦ គឺជាឯកសារដកស្រង់អង្គហេតុដែលបានមកពីសក្ខីកម្មជាលាយលក្ខណ៍អក្សរនៅក្នុងឧបសម្ព័ន្ធ ១ និង ២ ដោយបែងចែកតាមប្រភេទនៃអង្គហេតុនីមួយៗ។ ប្រភេទនៃអង្គហេតុទាំងនោះត្រូវបានបែងចែកជា៖ បរិបទជាប្រវត្តិសាស្ត្រដែលបង្កើតឱ្យមានរបបកម្ពុជាប្រជាធិបតេយ្យ [ឧបសម្ព័ន្ធ ៣] រចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យថ្នាក់មជ្ឈឹម [ឧបសម្ព័ន្ធ ៤] រចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន [ឧបសម្ព័ន្ធ ៥] វិធីសាស្ត្រនៃការប្រាស្រ័យទាក់ទងរបស់កម្ពុជាប្រជាធិបតេយ្យ [ឧបសម្ព័ន្ធ ៦] រចនាសម្ព័ន្ធយោធារបស់កម្ពុជាប្រជាធិតេយ្យ [ឧបសម្ព័ន្ធ ៧] ជម្លោះប្រដាប់អាវុធដែលកម្ពុជាប្រជាធិបតេយ្យបានចូលរួម [ឧបសម្ព័ន្ធ ៨] គោលនយោបាយនៃការបង្កើតការដ្ឋាន និងសហករណ៍ ដែលត្រូវបាន

[6] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន និងបញ្ហាភ័ស្តុតាងផ្សេងទៀត ឯកសារ **E208/2** ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២។

[7] ដូចយោងខាងលើ, ឯកសារ **E208/2.1**។

[8] សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី ១-១៦ ឯកសារ **E96/8** ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។

ដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ពន្ធ ៩] គោលនយោបាយនៃការបង្កើតការដ្ឋាន និងសហករណ៍ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បី សម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ពន្ធ ១០] គោលនយោបាយក្នុងការបង្កើតមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សនានាដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្ម រួម [ឧបសម្ពន្ធ១១] គោលនយោបាយដែលផ្តោតមុខសញ្ញាទៅលើក្រុមមនុស្សមួយជាក់លាក់ ដែលត្រូវបានដាក់ចេញនិងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ពន្ធ ១២] គោលនយោបាយក្នុងការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជន ដែលត្រូវបានដាក់ចេញ និងអនុវត្ត ដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ពន្ធ១៣] គោលនយោបាយក្នុងកាធ្វើទុក្ខបុកម្នេញ លើជនជាតិចាម ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ពន្ធ ១៤] គោលនយោបាយក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ពន្ធ ១៥] គោលនយោបាយក្នុងការ គ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហ ឧក្រិដ្ឋកម្មរួម[ឧបសម្ពន្ធ ១៦]។

៦. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក ខៀវ សំផន បានធ្វើការជំទាស់ទៅនឹងការណ៍ដែលសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមានចំនួនដ៏ច្រើនលើសលប់ អាចត្រូវបានបង្ហាញចំពោះមុខអង្គជំនុំជម្រះដើម្បីធ្វើការដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល[9]។ ដោយឡែក ពាក់ព័ន្ធនឹងសំណើសុំទីបី លោក ខៀវ សំផន បានលើកឡើងថា មានឯកសារសក្ខីកម្មដ៏ច្រើនសន្ធឹកសន្ធាប់បានប្រាសចាកពីក្របខណ្ឌនៃសំណុំរឿង ០០២/០១[10]។ ជាក់ស្តែង ឧបសម្ពន្ធជាច្រើនដែលបានដាក់ដោយសហព្រះរាជអាជ្ញា គឺជាឯកសារសក្ខីកម្មជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងអង្គហេតុដែលខ្វះនូវភាពសមហេតុសមផលសម្រាប់ដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០១។ ផ្ទុយទៅវិញ នៅខណៈដែលឧបសម្ពន្ធ ៣ ដល់ ៩[11] ដែលឧបសម្ពន្ធទាំងនោះពាក់ព័ន្ធ នឹងអង្គហេតុ

---

[9] មតិគាំទ្រសំណើរបស់លោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោលជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារ **E223** ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២។

[10] ដូចយោងខាងលើ កថាខណ្ឌ ២០។

[11] ឧបសម្ព័ន្ធ ៣ ដល់ ៩ នៃសំណើបន្ថែម (ឯកសារ **E96/8**) ស្តីពីប្រធានបទដូចតទៅៈ ឧបសម្ព័ន្ធ ៣ (*Historical background*

នៃរឿងក្ដីដែលកំពុងជំនុំជម្រះ បានយោងទៅលើសក្ខីកម្មចំនួន ៤០៦ ឧបសម្ព័ន្ធ ១០ ដល់ ១៦ ឯណោះវិញ បានបង្ហាញនូវសក្ខីកម្មដែលមានចំនួនដល់ទៅ ១៣៨៧ សក្ខីកម្ម។ ហេតុនេះ ហើយ សហមេធាវីការពារក្ដីលោក ខៀវ សំផន បានស្នើសុំដល់អង្គជំនុំជម្រះ ឱ្យបង្គាប់ដល់ការិយាល័យសហព្រះរាជអាជ្ញា ធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់នោះ។ មេធាវីការពារក្ដីសូមធ្វើការជំទាស់ផងដែរទៅលើភាពមិនប្រក្រតីនានាដែលកើតមានឡើងក្នុងអំឡុងពេលនៃការសួរយកចម្លើយសាក្សី ពីសំណាក់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។

៧. នៅក្នុងការឆ្លើយតបទៅវិញ កាលពីថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចេញនូវអនុស្សារណៈមួយដែលតាមរយៈនោះ៖(១). អង្គជំនុំជម្រះបានជូនដំណឹងដល់សហព្រះរាជអាជ្ញាថា មានតែសក្ខីកម្មដែលនឹងត្រូវបានជូនដំណឹងដល់ភាគីជាបីភាសាផ្លូវការរបស់ អ.វ.ត.ក មុនថ្ងៃសុក្រ ទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ទេ ដែលនឹងត្រូវបង្ហាញដល់អង្គជំនុំជម្រះដើម្បីដាក់បញ្ចូលក្នុងកិច្ចពិភាក្សា[12]។ ហើយ (២) អង្គជំនុំជម្រះបានជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីថា ដើមបណ្ដឹងរដ្ឋប្បវេណីមានពេលវេលារហូតដល់ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ ដើម្បីធ្វើការគូសបញ្ជាក់ឱ្យបានច្បាស់ ពាក់ព័ន្ធនឹងអ្វីដែលឯកសារនីមួយៗដែលត្រូវបានស្នើឱ្យដាក់បញ្ចូលក្នុងកិច្ចពិភាក្សា

---

*corroborative evidence*), ឧបសម្ព័ន្ធ ៤ (*Administrative structures (centre) corroborative evidence*), ឧបសម្ព័ន្ធ ៥ (*Administrative structures (national) corroborative evidence*), ឧបសម្ព័ន្ធ ៦ (*Communications structure corroborative evidence*), ឧបសម្ព័ន្ធ ៧ (*Military structure corroborative evidence*), ឧបសម្ព័ន្ធ ៨ (*Armed conflict corroborative evidence*), ឧបសម្ព័ន្ធ ៩ (*Movement of the population policy & widespread or systematic attack against the civilian population corroborative evidence*)។

[12] អនុស្សរណៈស្ដីពីសវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ ឯកសារ **E223/2** ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៩។

ចង់បង្ហាញ និងដើម្បីធ្វើការចង្អុលបង្ហាញថាតើសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះ ដែលខ្លួនមានបំណងស្នើសុំឲ្យដាក់បញ្ចូលក្នុងកិច្ចពិភាក្សា ទុកជាឯកសារភស្តុតាងនោះ[13]។

៨. នៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះក៏បាន "*ធ្វើការសម្រេចផងដែរថា អង្គជំនុំជម្រះអាចធ្វើការពិនិត្យលើសេចក្តីជំទាស់ដែលលើកឡើងដោយភាគី*<u>*នៅក្នុងអំឡុងពេលស្តាប់សក្ខីកម្មរបស់សាក្សី*</u> *នាអង្គសវនាការ ដរាបណាសេចក្តីជំទាស់ទាំងនេះមានលក្ខណៈច្បាស់លាស់ និងមានសម្អាងហេតុគ្រប់គ្រាន់ ហើយមានមូលដ្ឋានផ្អែកលើភាពខុសគ្នាយ៉ាងជាក់ច្បាស់រវាងខ្លឹមសារនៃកំណត់ហេតុ និងខ្លឹមសារនៃឯកសារថតសម្លេងដែលបានធ្វើក្នុងអំឡុងពេលស៊ើបសួរ។*"[14]។ ការដែលទទួលយកទាំងដុំៗ នូវឯកសារសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សីដែលមានចំនួនរាប់ពាន់ទំព័រ ហើយដែលសាក្សីទាំងនោះពុំបានចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះផង បានធ្វើឲ្យសហមេធាវីបាត់បង់លទ្ធភាពក្នុងការត្រួតពិនិត្យលើឯកសារទាំងនោះ ហេតុដូច្នេះហើយសហមេធាវីមិនអាចលើកឡើងនូវសេចក្តីជំទាស់ដែលមានប្រយោជន៍ដល់ការការពារក្តីរបស់ខ្លួនបានឡើយ។

៩. បន្ទាប់ពីមានមោឃភាពលើដីកាបំបែកសំណុំរឿងទីមួយពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") និងមុនពេលដែលដីកាបំបែកសំណុំរឿងថ្មីត្រូវបានចេញដោយអង្គជំនុំជម្រះ សហព្រះរាជអាជ្ញាបានស្នើសុំដល់មន្ត្រីច្បាប់ជាន់ខ្ពស់ដើម្បីផ្តល់ពេលវេលាបន្ថែមដល់ពួកគេដើម្បីធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់ខ្លួន។ សហព្រះរាជអាជ្ញាបានលើកឡើងថាខ្លួនអាចបញ្ចប់ការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរបាន ដរាបណាដីកាបំបែកសំណុំ

---

[13] ដូចយោងខាងលើ កថាខណ្ឌ ១៣។

[14] សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារ E221, E224, E224/2, E234, E234/2, E241 និង E241/1) ឯកសារ E251 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២៦។

រឿងថ្មីត្រូវបានចេញដោយអង្គជំនុំជម្រះ[15]។ អង្គជំនុំជម្រះពុំបានទទួលយកសំណើសុំនេះឡើយ ហើយបានរក្សាទុកកាលបរិច្ឆេទដូចដែលបានកំណត់ពីពេលមុនមក[16]។

១០. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានដាក់នូវសេចក្តីសន្និដ្ឋាន ដោយជូនដំណឹងដល់អង្គជំនុំជម្រះថា ៥ ភាគរយ នៃឯកសារដែលត្រូវបានស្នើសុំឱ្យបកប្រែ ពុំទាន់ត្រូវបានបកប្រែនៅឡើយ ប៉ុន្តែឯកសារទាំងនោះនឹងត្រូវបានបកប្រែរួចរាល់នាខែ មិថុនា ឆ្នាំ ២០១៣[17]។ ដោយឡែក សហព្រះរាជអាជ្ញាពុំបានផ្ញើជូនអង្គជំនុំជម្រះ និងជូនដល់ភាគីទាំងអស់នៃរឿងក្តី នូវបញ្ជីកែតម្រូវសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់ខ្លួនឡើយ។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ត្រូវបានបង្ខំឱ្យធ្វើសេចក្តីជំទាស់របស់ខ្លួនដោយផ្អែកលើមូលដ្ឋាននៃបញ្ជីសក្ខីកម្មដែលសហព្រះរាជអាជ្ញាមិនទាន់កែតម្រូវនៅឡើយ ។

១១. នៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានដាក់នូវបញ្ជីចុងក្រោយមួយរបស់ខ្លួនចំនួន ១៨៧ ទំព័រ ដែលសុទ្ធសឹងជាសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលពុំត្រូវបានស្តាប់ចម្លើយនៅក្នុងអំឡុងសវនាការ[18]។

១២. ទើបតែនៅថ្ងៃទី ១០ ខែ មេសា ទេ ដែលឧបសម្ពន្ធកែតម្រូវនានារបស់សហព្រះរាជអាជ្ញាត្រូវបានផ្ញើជូនអង្គជំនុំជម្រះ និងភាគីនៃរឿងក្តី។ ដោយគិតអំពីកាតព្វកិច្ចដែលភាគីនីមួយៗ នៃរឿងក្តីត្រូវធ្វើការបកប្រែឯកសារដែលខ្លួនមានបំណងដាក់ ទង្វើរបស់ព្រះរាជអាជ្ញាក្នុងការរំលោភលើកាលបរិច្ឆេទដែលកំណត់ដោយអង្គជំនុំជម្រះដើម្បីឱ្យសហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីរសក្ខី

[15] អ៊ីមែលរបស់លោក William SMITH ផ្ញើជូនលោកស្រី Susan LAMB នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ វេលាម៉ោង ១០ និង ០៥ នាទី កម្មវត្ថុ៖ « *Re : Proposed procedure for Defence objections to the admission of written statements* »។

[16] អ៊ីមែលរបស់លោកស្រី Susan LAMB ផ្ញើជូនលោក William SMITH នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១០ និង ០៤ នាទី កម្មវត្ថុ៖ « *Re : OCP witness statements proposed for admission* »។

[17] សំណើរបស់សហព្រះរាជអាជ្ញាសុំបង្កើតនីតិវិធីពាក់ព័ន្ធនឹងការទទួលយកឯកសារ ដែលមិនបានបកប្រែគ្រប់ភាសាទាំងអស់របស់ អ.វ.ត.ក ឯកសារ **E223/2/6** ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[18] ឧបសម្ព័ន្ធសម្ងាត់ទី ១៖ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ឯកសារ **E223/2/7.2** ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣។

កម្មជាលាយលក្ខណ៍អក្សររបស់ខ្លួន បានរាំងខ្ទប់មេធាវីការពារក្តីលោក ខៀវ សំផន មិនឱ្យគាត់តែង សេចក្តីជំទាស់របស់ខ្លួន ដោយផ្អែកលើមូលដ្ឋាននៃបញ្ជីកែតម្រូវរបស់សហព្រះរាជអាជ្ញា បាន។ ដោយហេតុថា សហព្រះរាជអាជ្ញាពុំបានបំពេញការងាររបស់ខ្លួនដោយយកចិត្តទុកដាក់ នោះ សេចក្តីជំទាស់របស់លោក ខៀវ សំផន ទាំងនេះ បានផ្អែកលើបញ្ជីសក្ខីកម្មរបស់សហព្រះរាជអាជ្ញា ដែលមានពីមុនមកប៉ុណ្ណោះ។

១៣. កម្មវត្ថុនៃសេចក្តីជំទាស់នេះ គឺសំដៅធ្វើការបង្ហាញ ដោយអនុលោមតាមសេចក្តីណែនាំរបស់ អង្គជំនុំជម្រះ នូវសេចក្តីជំទាស់ប្រកបដោយហេតុផល និងមានលក្ខណៈលម្អិត ប្រឆាំងទៅនឹងការ សម្រេចដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សា នូវឯកសារសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមានចំនួនដ៏ ច្រើនសន្ធឹកសន្ធាប់ ដែលបានស្នើដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុង សំណើសុំទាំងឡាយដែលបានបញ្ជាក់ខាងលើ។ សេចក្តីជំទាស់នេះគឺសម្រាប់អានរួមគ្នាជាមួយនឹង សំណើសុំទាំងឡាយដែលបានដាក់រួចមកហើយដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ ព័ន្ធនឹងច្បាប់ដែលត្រូវអនុវត្តលើករណីដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល នូវឯកសារសក្ខី កម្មជាលាយលក្ខណ៍អក្សរ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់នោះ[19]។

១៤. បើតាមការយល់ឃើញរបស់សហមេធាវីការពារក្តីលោក ខៀវ សំផន ឧបសម្ពន្ធដែលជាសក្ខីកម្ម លាយលក្ខណ៍អក្សរទាំងមូលគួរតែត្រូវបានប្រកាសថាពុំមានលក្ខណៈសមស្រប ដោយយោងទៅ លើប្រភេទនៃអង្គហេតុដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ ដែលវិសាលភាពនៃសំណុំរឿងនេះ ត្រូវ បានទទួលស្គាល់តាមរយៈសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះ កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣។ ដោយឡែក អត្ថបទដកស្រង់សក្ខីកម្មមួយចំនួនមានការជាប់ពាក់ព័ន្ធនឹងប្រភេទ នៃអង្គហេតុដែលគេមិនអាចបង្ហាញបានតាមរយៈសក្ខីកម្មជាលាយលក្ខណ៍អក្សរតែមួយគត់ ដោយ ពុំមានការផ្តល់សក្ខីកម្មផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ។

---

[19] សេចក្តីសន្និដ្ឋានអនុលោមតាមវិធាន ៩២ អំពីច្បាប់អនុវត្តលើការទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ ជំនួសឱ្យ សក្ខីកម្មផ្ទាល់មាត់ ឯកសារ E277 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣។

១៥. កម្មវត្ថុនៃផ្នែកទាំងឡាយបន្តបន្ទាប់ខាងក្រោមនេះ គឺសំដៅធ្វើការបង្ហាញនូវគោលការណ៍នាំមុខមួយចំនួន ដែលតាមរយៈនោះគេអាចតាក់តែងនូវសេចក្តីជំទាស់ទៅនឹងឧបសម្ពន្ធនីមួយៗ។ ឧបសម្ពន្ធទាំងនេះត្រូវបានភ្ជាប់ទៅនឹងសេចក្តីជំទាស់ រួមទាំងសេចក្តីអត្ថាធិប្បាយនានាលើអត្ថបទដកស្រង់សក្ខីកម្មនីមួយៗ។

## ១. សំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យមានការដាក់បញ្ចូលនៅក្នុងកិច្ចពិភាក្សានូវសក្ខីកម្មជាលាយលក្ខណ៍អក្សរជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់

### ក. សំណើសុំដំបូងទាំងពីររបស់សហព្រះរាជអាជ្ញា: សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងដំណាក់កាលទី ១ និងទី ២ នៃការជម្លៀសប្រជាជន

១៦. ឧបសម្ពន្ធដំបូងទាំងពីរនៃសំណើសុំទីមួយរបស់សហព្រះរាជអាជ្ញា គឺជាឯកសារដកស្រង់សក្ខីកម្មនានាដែលពាក់ព័ន្ធទៅនឹងអង្គហេតុទាំងឡាយដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។ ផ្ទុយទៅវិញ សក្ខីកម្មមួយចំនួនមានជាប់ពាក់ព័ន្ធទៅនឹងប្រភេទនៃអង្គហេតុដែលត្រូវទាមទារឲ្យមានការចោទសួរឡើងវិញទៅលើសាក្សី ដើម្បីផ្ទៀងផ្ទាត់អំពីភាពស៊ីសង្វាក់នៃសក្ខីកម្មជាលាយលក្ខណ៍អក្សរនោះ។

១៧. ដូចដែលលោក ខៀវ សំផន បានគូសបញ្ជាក់ក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនពាក់ព័ន្ធនឹងច្បាប់ដែលត្រូវអនុវត្តលើករណីដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល នូវសក្ខីកម្មជាលាយលក្ខណ៍អក្សរ សក្ខីកម្មទាំងឡាយដែលពាក់ព័ន្ធនឹងទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទ មិនអាចត្រូវបានដាក់បញ្ចូលក្នុងកិច្ចពិភាក្សាដេញដោលដោយពុំបានផ្តល់ឱកាសដល់មេធាវីការពារក្តីធ្វើការសាកសួរផ្ទៀងផ្ទាត់ជាមួយនឹងម្ចាស់សក្ខីកម្មជាមុននោះឡើយ។ បើពុំដូច្នោះទេ សក្ខីកម្មអស់ទាំងនេះត្រូវតែបានបដិសេធចោល[20]។

[20] ដូចយោងខាងលើ កថាខណ្ឌ ១៨ ដល់កថាខណ្ឌ ២៦។

១៨. ដើម្បីឲ្យសេចក្តីជំទាស់របស់ខ្លួនមានលក្ខណៈលម្អិត ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានយោងទៅលើសំណើររបស់ខ្លួនដែលតាមរយៈនោះ ក្រុមមេធាវីការពារក្តីធ្លាប់បានរំលឹកថា រាល់ទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទត្រូវតែបានពិចារណាតាមន័យទូលាយ ជាពិសេសក្នុងក្របខណ្ឌនៃរឿងក្តីដែលការទទួលខុសត្រូវតាមឋានានុក្រម និងការចូលរួមរបស់ជនជាប់ចោទទៅក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវបានចោទប្រកាន់[21] និងង្កើតបានជាចំណុចស្នូលនៃការចោទប្រកាន់ពីសំណាក់សហព្រះរាជអាជ្ញា។

១៩. មេធាវីការពារក្តីលោក ខៀវ សំផន សូមប្រឆាំងទៅនឹងការទទួលយកឯកសារសក្ខីកម្មទាំងឡាយដែលពាក់ព័ន្ធនឹងទង្វើ ព្រមទាំងសកម្មភាពរបស់ជនជាប់ចោទ រួមទាំងរចនាសម្ពន្ធចេញសេចក្តីសម្រេចរបស់កម្ពុជាប្រជាធិបតេយ្យ និងរចនាសម្ពន្ធរដ្ឋបាលមូលដ្ឋាន ទុកជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង ដោយពុំបានផ្តល់ឱកាសដល់មេធាវីការពារក្តីដើម្បីសួរដេញដោលលើម្ចាស់សក្ខីកម្ម ខណៈដែលសក្ខីកម្មទាំងនោះ មានចរិតជាការបង្ហាញអំពីអត្ថិភាពនៃចំណងពាក់ព័ន្ធឋានានុក្រមជាមួយនឹងអង្គភាព "មជ្ឈិម" នោះ[22]។

២០. ដោយឡែក សហមេធាវីការពារក្តីលោក ខៀវ សំផន បានរំលឹកនៅក្នុងឯកសារសំណើរដដែលថា សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើការបង្ហាញគោលបំណងរបស់ខ្លួនតាមរយៈសក្ខីកម្មជាលាយលក្ខណ៍អក្សរបានឡើយ ខណៈដែលភាគីនៃរឿងក្តីត្រូវប្រឈមមុខនឹងបញ្ហាអង្គច្បាប់ ហើយដែលករណីនេះមិនទាន់ត្រូវបានដាក់ឲ្យពិភាក្សាដេញដោលចំពោះមុខនៅឡើយនោះ[23]។

២១. ជាក់ស្តែង សក្ខីកម្មមួយចំនួនធំដែលស្នើឡើងដោយសហព្រះរាជអាជ្ញា មានគោលដៅបង្ហាញថាលក្ខណវិនិច្ឆ័យទូទៅទាំងឡាយ ដែលប្រើសម្រាប់កំណត់បទល្មើសនានាដូចបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញ។ ទន្ទឹមគ្នានេះ ត្រូវបានស្នើផងដែរ សក្ខីកម្មទាំង

---

[21] ដូចយោងខាងលើ។

[22] ដូចយោងខាងលើ។

[23] ដូចយោងខាងលើ កថាខណ្ឌ ២៧ ដល់កថាខណ្ឌ ៣៧។

ឡាយដែលមានគោលដៅបង្ហាញអំពីអត្ថិភាពនៃចេតនារើសអើងចំពោះ "ប្រជាជន ១៧ មេសា" និង "ក្រុមខ្មែរសាធារណរដ្ឋ" ។ លោក ខៀវ សំផន សូមធ្វើការប្រឆាំងទៅនឹងការចោទប្រកាន់ដែលថាមានចេតនារើសអើងណាមួយនោះ។ លោកក៏បានរំលឹកផងដែរថា បញ្ហានេះ ដែលបានប្រឆាំងទៅនឹងភាគីនៃរឿងក្តី ពុំទាន់ត្រូវបានធ្វើជាកម្មវត្ថុនៃការពិភាក្សាដេញដោលចំពោះមុខនាអង្គសវនាការនៅឡើយទេ។ ហេតុដូច្នេះ ដោយអនុលោមទៅតាមបទបញ្ញត្តិដែលត្រូវអនុវត្ត មេធាវីការពារក្តីសូមធ្វើការជំទាស់ទៅនឹងការណ៍ដែលថា សក្ខីកម្មទាំងនេះត្រូវបានប្រកាសថាអាចទទួលយកបាន នៅខណៈដែលអ្នកផ្តល់សក្ខីកម្មពុំត្រូវបានគេកោះហៅឲ្យចូលខ្លួនមកនៅចំពោះមុខអង្គជំនុំជម្រះទេនោះ។

## ខ. <u>សំណើសុំនីតិវិធីរបស់សហព្រះរាជអាជ្ញា: ឧបសម្ព័ន្ធសម្ងាត់ពី ១ ដល់ ១៦</u>

## គ. <u>បរិបទប្រវត្តិសាស្ត្រនៃការករកើតរបបកម្ពុជាប្រជាធិបតេយ្យ (ឧបសម្ព័ន្ធ ៣)</u>

២២. ឯកសារដកស្រង់សក្ខីកម្មរបស់សាក្សី ដែលពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រមានលក្ខណៈសមហេតុផល ប៉ុន្តែមានឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនោះពាក់ព័ន្ធទៅនឹងទង្វើ និងសកម្មភាពរបស់ជនជាប់ចោទ។

២៣. ដូចដែលក្រុមមេធាវីការពារក្តីទាំងអស់បានលើកឡើងរួចមកហើយ វាជាតួនាទីរបស់សហព្រះរាជអាជ្ញា ហើយពុំមែនរបស់អង្គជំនុំជម្រះទេ ក្នុងការជ្រើសរើសយកផ្នែកណាមួយនៃសក្ខីកម្មដែលមានលក្ខណៈអាចទទួលយកបាន។ នៅខណៈដែលសហព្រះរាជអាជ្ញាពុំទាន់បានធ្វើការញែកសក្ខីកម្មទាំងនោះនៅឡើយទេ មេធាវីការពារក្តីលោក ខៀវ សំផន សូមធ្វើការប្រឆាំងទៅនឹងការដាក់បញ្ចូលសក្ខីកម្មដែលពាក់ព័ន្ធនឹងទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ក្នុងកិច្ចពិភាក្សាដេញដោលទាំងមូល។

## ឃ. <u>ឧបសម្ព័ន្ធដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងយោធារបស់កម្ពុជាប្រជាធិបតេយ្យ [ឧបសម្ព័ន្ធ ៤, ៥, ៦ និង ៧]</u>

២៤. សក្ខីកម្មដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងអំពីវិធីសាស្រ្តនៃការប្រាស្រ័យទាក់ទង មានគោលដៅបង្ហាញអំពីធាតុផ្សំនៃបែបផែននៃការចូលរួមដែលតាមរយៈនោះ សហព្រះរាជអាជ្ញាមានបំណងបង្ហាញអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ។

២៥. វាមានលក្ខណៈជារឿងប្រឌិតពីសំណាក់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញអំពីភាពខុសគ្នារវាងសក្ខីកម្មដែលពាក់ព័ន្ធនឹងទង្វើ ព្រមទាំងសកម្មភាពរបស់ជនជាប់ចោទ និងសក្ខីកម្មដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល យោធា និងអំពីវិធីសាស្រ្តនៃការប្រាស្រ័យទាក់ទង។ អង្គជំនុំជម្រះមិនអាចសម្រេចទទួលយកការបែងចែកនេះ ដោយពុំបានរំលោភលើសិទ្ធិជាមូលដ្ឋានរបស់មេធាវីការពារក្នុងការសួរដេញដោលទៅលើសាក្សីពាក់ព័ន្ធនឹងភស្តុតាងសំខាន់ដែលលើកឡើងដោយសហព្រះរាជអាជ្ញាឡើយ។

២៦. ហេតុដូច្នេះ លោក ខៀវ សំផន សូមធ្វើការប្រឆាំងទៅនឹងការដាក់បញ្ចូលឯកសារសក្ខីកម្មទាំងមូលដែលមាននៅក្នុងឧបសម្ព័ន្ធ ៤ ៥ ៦ និង៧ នៃសំណើសុំទីបីរបស់សហព្រះរាជអាជ្ញា ទៅក្នុងកិច្ចពិភាក្សាជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់នោះ។

## ខ. ឧបសម្ព័ន្ធដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធដែលកម្ពុជាប្រជាធិបតេយ្យបានចូលរួម [ឧបសម្ព័ន្ធ ៨]

២៧. ពាក់ព័ន្ធនឹងឧបសម្ព័ន្ធនេះ មានតែសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ដែលបានកើតឡើងដំណាលគ្នានឹងបទល្មើសនានាដូចបានចោទប្រកាន់ (ពោលគឺរវាងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់១៩៧៦) និងដោយមានជាប់ទាក់ទងជាមួយឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ក្នុងក្របខណ្ឌនៃសំណុំរឿងទីមួយទេ ដែលត្រូវបានមើលឃើញថាមានលក្ខណៈសមហេតុសមផលនោះ។ ដោយឡែក ពាក់ព័ន្ធនឹងចំណុចវិវាទរវាងភាគីនៃរឿងក្តី ការចូលខ្លួនមកផ្តល់សក្ខីកម្មផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះគឺជារឿងមួយចាំបាច់។ អត្ថិភាពនៃជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម ក្រោយកាលបរិច្ឆេទនេះ មិនស្ថិតនៅក្នុងវិសាលភាពនៃរឿងក្តីដូចដែលបានកំណត់ដោយអង្គជំនុំជម្រះនៅក្នុង “បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាបញ្ជូនរឿងទៅជំនុំ

ជម្រះ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១”[24]។ កំណត់សម្គាល់នានាដែលលើកឡើងនៅក្នុងកថាខណ្ឌក្រោយៗទៀត ពាក់ព័ន្ធនឹងភាពសមស្របនៃឧបសម្ព័ន្ធ ១០ ដល់ ឧបសម្ព័ន្ធ ១៦ ក៏អនុវត្តផងដែរទៅលើករណីនៃឧបសម្ព័ន្ធ ៨ ព្រមទាំងឧបសម្ព័ន្ធ E208.1, E208.2 និង E208/2.1 ដែលភ្ជាប់ជាមួយសំណើសុំទាំងពីរដំបូង របស់សហព្រះរាជអាជ្ញា។

ច. “គោលនយោបាយ”៖ គោលនយោបាយជម្លៀសប្រជាជន ដែលត្រូវបានដាក់ចេញ និងអនុវត្ត ដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ព័ន្ធ ៩]។ គោលនយោបាយបង្កើតការដ្ឋាន និងសហករណ៍ ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ព័ន្ធ ១០]។ គោលនយោបាយបង្កើតមន្ទីរសន្តិសុខ និង កន្លែងសម្លាប់មនុស្ស ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហ ឧក្រិដ្ឋកម្មរួម [ឧបសម្ព័ន្ធ ១១]។ គោលនយោបាយដែលផ្តោតមុខសញ្ញាទៅលើក្រុមមនុស្សមួយជាក់លាក់ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ព័ន្ធ ១២] គោលនយោបាយក្នុងការធ្វើទុក្ខបុកម្នេញលើ ពុទ្ធសាសនិកជន ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ព័ន្ធ ១៣] គោលនយោបាយក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិចាមដែល ត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ព័ន្ធ១៤] គោលនយោបាយក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម ដែលត្រូវបានដាក់ ចេញនិងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ព័ន្ធ ១៥] គោលនយោបាយ ក្នុងការចេញបទបញ្ជាពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវបានដាក់ចេញ និងអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម [ឧបសម្ព័ន្ធ ១៦]

---

[24] ឧបសម្ព័ន្ធនៃ “សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីល័ក្ខខ័ណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ” មានចំណងជើងថា “បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163)” ឯកសារ **E124/7.3** ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១។

## ក. ការរំលឹកអំពីនីតិវិធីពាក់ព័ន្ធនឹង "គោលនយោបាយនាំង ៥"

២៨. នៅក្នុងដីកាបំបែកសំណុំរឿងពីដំបូងរបស់ខ្លួន អង្គជំនុំជម្រះបានកំណត់វិសាលភាពនៃសំណុំរឿងទីមួយត្រឹមការជម្លៀសប្រជាជនក្នុងដំណាក់កាល ១ និង ២ ហើយបានបញ្ជាក់យ៉ាងច្បាស់ថា "*អង្គហេតុពាក់ព័ន្ធនឹងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬអង្គហេតុពាក់ព័ន្ធ និងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី ៣ នឹងមិនត្រូវបានលើកយកមកជម្រះដោលនៅក្នុងការជំនុំជម្រះលើកដំបូងនេះទេ។ លើសពីនេះទៅទៀត បទចោទប្រកាន់ទាំងអស់ដូចជាបទប្រល័យពូជសាសន៍ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ត្រូវទុកដើម្បីលើកយកទៅជម្រះដោលនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក្រោយៗទៀតនៅក្នុងសំណុំរឿង ០០២។*[25] នៅក្នុងឧបសម្ពន្ធនៃសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះបានលើកឡើងថា ការពិនិត្យលើគោលនយោបាយទាំងឡាយដែលបានដាក់ចេញ *នឹងត្រូវកម្រិតត្រឹមតែការជម្លៀសប្រជាជនក្នុងដំណាក់កាល ១ និង ២ ប៉ុណ្ណោះ*[26]។

២៩. ក្នុងការសម្រេចតាមសំណើសុំរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានលាតសន្ធឹងវិសាលភាពនៃសំណុំរឿងទីមួយរហូតដល់ទីកន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះបានសម្រេចថា "*ការកាប់សម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃដែលបានកើតឡើងភ្លាមៗបន្ទាប់ពីការដួលរលំនៃរបបក្រុងភ្នំពេញ គឺជាការពង្រីកវិសាលភាពសមស្របនៃការចោទប្រកាន់ដែលមានស្រាប់នៅក្នុងសំណុំរឿង ០០២/០១ ហើយការដាក់បញ្ចូលអង្គហេតុនៃការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃនេះមិនបានពន្យាពេលកិច្ចដំណើរការជំនុំជម្រះហួសហេតុនោះទេ*"[27]។ នៅក្នុងឧបសម្ពន្ធ

---

[25] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួន*ពីរនៃវិធានផ្ទៃក្នុង ឯកសារ **E124** ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៧។

[26] ដូចយោងខាងលើ, ឯកសារ **E124/7.3** ទំព័រ ២។

[27] អនុស្សរណៈស្តីពី៖ "សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន" ឯកសារ **E163/5** ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ

សេចក្តីជំទាស់របស់លោក ខៀវ សំផនទៅនឹងការដាក់បញ្ចូលក្នុងកិច្ចពិភាក្សានូវសក្ខីកម្មជាលាយលក្ខណ៍អក្សរមួយចំនួនដែលស្នើដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់

នៃសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះបានចង្អុលបង្ហាញកថាខណ្ឌនានានៃដីកាដំណោះស្រាយ "*កម្មវត្ថុនៃសំណុំរឿងទីមួយ ក្នុងក្របខណ្ឌនៃសំណុំរឿង ០០២*"។ ពាក់ព័ន្ធនឹង "*គោលនយោបាយដែលត្រូវបានដាក់ចេញដើម្បីសម្រេចនូវផែនការណ៍រួម*" អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា កថាខណ្ឌទាំងឡាយដែលមានលក្ខណៈសមស្របត្រូវបានកម្រិតត្រឹម "*ការជម្លៀសប្រជាជន (**អង្គជំនុំជម្រះពិនិត្យត្រឹមតែ**ដំណាក់កាលទី ១ និងទី ២) (កថាខណ្ឌ ១៦០ ដល់ ១៦៥) និង វិធានការណ៍ប្រឆាំងនឹងក្រុមមនុស្សជាក់លាក់ (**អង្គជំនុំជម្រះពិនិត្យត្រឹមតែ**វិធានការណ៍ដែលប្រឆាំងនឹងយោធា និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទីកន្លែងកាប់សម្លាប់មនុស្សទួលពោធិ៍ជ្រៃ[28])*"។ ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវ អង្គជំនុំជម្រះបានដាក់បញ្ចូលការទទួលខុសត្រូវ ដែលកើតចេញមកអំពីសហឧក្រិដ្ឋកម្មរួម ទៅក្នុងវិសាលភាពនៃសំណុំរឿងទីមួយ ប៉ុន្តែ "***លើកលែងរាល់ករណីដែលពាក់ព័ន្ធនឹង**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ព្រមទាំងវាក្យខណ្ឌទាំងឡាយដែលមានចំណងជើងថា "ការបង្កើត និងការប្រព្រឹត្តទៅនៃ សហករណ៍ និងការដ្ឋាន" "ការអប់រំសមាសភាពមិនល្អ និងការកម្ទេចខ្មាំងរបស់អង្គការ ទាំងខ្មាំងដែលបង្កប់ក្នុងជួរបក្ស ទាំងខ្មាំងពីខាងក្រៅ" និង"ការគ្រប់គ្រងលើអាពាហ៍ពិពាហ៍" ) ហើយពិចារណាតែទៅលើករណីយោធា និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពាក់ព័ន្ធនឹងវាក្យខណ្ឌដែលមានចំណងជើងថា "ការចាត់វិធានការណ៍ដោយឡែកប្រឆាំងទៅនឹងក្រុមមនុស្សជាក់លាក់មួយចំនួន ជាពិសេសជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតមន្ត្រីនៃរបប សាធារណរដ្ឋខ្មែរ (មន្ត្រីរដ្ឋការ យោធា និងក្រុមគ្រួសាររបស់ពួកគេ)*[29]។ សហព្រះរាជអាជ្ញាចង់លើកឡើងអំពីសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធជាពិសេស តែទៅលើចំណុចទាំងនេះតែ ប៉ុណ្ណោះ (ឧបសម្ព័ន្ធ ១០ដល់ ១៦ នៃឯកសារ E96/8)។

៣០. បន្ទាប់ពីមានសេចក្តីសម្រេចនេះ សហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះឱ្យធ្វើការបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿងទីមួយ ហើយបញ្ជាក់ថា "*(១) គោលនយោបាយទាំងប្រាំដែលបង្កើតបានជាគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមហើយនិងតួនាទី និងការចូលរួមរបស់ជនជាប់ចោទ*

---

២០១២ កថាខណ្ឌ ៣។

[28] ដូចយោងខាងលើ, ឯកសារ **E124/7.3** ទំព័រ ២។

[29] ដូចយោងខាងលើ, ឯកសារ **E124/7.3** ទំព័រ ៥។

*នៅក្នុងគោលនយោបាយទាំងនេះគឺជាបញ្ហាជាក់ស្តែងនៅក្នុងសវនាការលើកដំបូង។ ។ និង (២) ថាបញ្ហាទាំងនេះ ដែលតម្រូវឱ្យមានការសួរដេញដោល ដែលជាសក្ខីភាពដែលសំដៅឆ្ពោះទៅរក កម្រិតដែលតម្រូវឱ្យមាន ដែលអាស្រ័យហេតុនេះ ត្រូវមានការសួរដេញដោល និងការទទួលយក នូវភ័ស្តុតាងជាឯកសារ។"*[30]។

៣១. អង្គជំនុំជម្រះបានឆ្លើយតបវិញថា៖ "*ការពិនិត្យលើភ័ស្តុតាងក្នុងក្របខណ្ឌនៃសំណុំរឿងទីមួយ នឹងត្រូវធ្វើទៅលើគោលនយោបាយនៃការជម្លៀសប្រជាជន (ដំណាក់កាលទី ១ និងទី ២)។ ដោយឡែក អង្គជំនុំជម្រះក៏អាចធ្វើការពិនិត្យផងដែរ ក្នុងអំឡុងពេលសវនាការលើរឿងនេះ លើគោលនយោបាយផ្សេងទៀតដែលបានរៀបរាប់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងករណីតែមួយគត់ដែលអង្គជំនុំជម្រះចង់បង្ហាញអំពីរបៀបដែលគោលនយោបាយ [នៃការជម្លៀសប្រជាជនដោយបង្ខំ] នោះត្រូវបានបង្កើតឡើង។ ដូច្នេះ អ្វីដែលរំពឹងទុកគឺការបង្ហាញជាទូទៅអំពីគោលនយោបាយទាំងប្រាំ ទោះបីជាបញ្ហាជាក់ស្តែងសម្រាប់សួរដេញដោល នៅក្នុងសវនាការដំណាក់កាលដំបូងត្រូវបានកម្រិតនៅត្រឹមការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី ១ និងទី ២) យ៉ាងណាក៏ដោយ។ ដូច្នេះ វានឹងមិនមានការពិនិត្យលើការអនុវត្តគោលនយោបាយផ្សេងក្រៅអំពីគោលនយោបាយដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី ១ និងទី ២)ឡើយ។*"[31]។

៣២. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានទទួលស្គាល់សេចក្តីសម្រេចរបស់ខ្លួនក្នុងការកម្រិតវិសាលភាពនៃសំណុំរឿងទីមួយមកនៅត្រឹមការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី ១ និងទី ២) និងត្រឹមតែកន្លែងកាប់សម្លាប់មនុស្សទួលពោធិ៍ជ្រៃប៉ុណ្ណោះ[32]។

---

[30] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង ឯកសារ **E124/9** ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ៨។

[31] អនុស្សរណៈស្តីពី "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១" ឯកសារ **E141** ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៣។

[32] ប្រតិចារឹកសវនាការ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **E1/176.1**។

៣៣. ដោយផ្អែកលើវិសាលភាពនៃសំណុំរឿងដែលបានកំណត់ដោយអង្គជំនុំជម្រះ គេត្រូវពិនិត្យលើភាពសមស្របនៃសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។

## ខ. ភាពសមស្របនៃសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងគោលនយោបាយ

៣៤. ដូចដែលទើបនឹងបានរំលឹក អង្គជំនុំជម្រះបានកម្រិតយ៉ាងជាក់ច្បាស់នូវវិសាលភាពនៃរឿងក្តីត្រឹមគោលនយោបាយដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ។ ជាក់ស្តែង នាពេលបច្ចុប្បន្ននេះ សហព្រះរាជអាជ្ញាបានសាកល្បងធ្វើឲ្យហួសព្រំដែនដែលបានកម្រិតដោយអង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេចបំបែកសំណុំរឿងរបស់ខ្លួន។ សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា សក្ខីកម្មជាលាយលក្ខណ៍អក្សរទាំងឡាយដែលសហព្រះរាជអាជ្ញាមានបំណងបង្ហាញ *មានជាប់ពាក់ព័ន្ធទៅនឹងទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម**ដែលពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងទីមួយ** នៃសំណុំរឿង ០០២ ឡើយ* ”[33]។ ចំណុចនេះមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឲ្យមានការដកសក្ខីកម្មជាលាយលក្ខណ៍អក្សរទាំងនេះចេញពីកិច្ចពិភាក្សាដេញដោល។

៣៥. ជាក់ស្តែង ផ្អែកលើវិធាន ៩៨ នៃវិធានផ្ទៃក្នុង “*អង្គជំនុំជម្រះសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។* ក្នុងការដែលដកចេញពីសំណុំរឿងទីមួយ នូវរាល់កថាខណ្ឌនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានលក្ខណៈសមស្របទៅនឹងគោលនយោបាយផ្សេង ក្រៅអំពីការជម្លៀសប្រជាជន អង្គជំនុំជម្រះហាក់ដូចជាច្រានចោលអង្គហេតុទាំងនេះដោយផ្អែកតាមព្រឹត្តន័យ (*de facto*)។ អង្គជំនុំជម្រះមិនអាចចេញសេចក្តីសម្រេច ដោយផ្អែកលើសម្អាងហេតុបានមកអំពីកថាខណ្ឌនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចបំបែកសំណុំរឿងរបស់ខ្លួន ដោយពុំបានរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះឡើយ។ កំណត់សម្គាល់នេះក៏អនុវត្តដូចគ្នាផងដែរទៅលើឧបសម្ពន្ធដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ។ ដូច្នេះ សក្ខីកម្មជាលាយ

[33] ដូចយោងខាងលើ, ឯកសារ **E96/8** កថាខណ្ឌ ១២។

លក្ខណ៍អក្សរដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ៨ និង ១០ ដល់ ១៦ ពុំមានភាពសមស្របឡើយ (លើកលែងតែសក្ខីកម្មដែលមាននៅក្នុងឧបសម្ព័ន្ធ ១២ ដែលមានគោលដៅបង្ហាញអំពីវិធានការណ៍ជាក់លាក់ អនុវត្តមកលើអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ)។

៣៦. ជាក់ស្តែង សហព្រះរាជអាជ្ញាបានប៉ុនប៉ងដោយឥតប្រយោជន៍ក្នុងការពន្លាតវិសាលភាពនៃរឿងក្តីដោយលើកអំណះអំណាងថា សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមាននៅក្នុងបញ្ជីនៃឧបសម្ព័ន្ធ ៣ ដល់ ១៦ "*មានលក្ខណៈសមស្រប ដោយហេតុថា សក្ខីកម្មទាំងនោះបានរួមចំណែកដល់ការបង្ហាញនូវការកកើតនៃគោលនយោបាយដែលត្រូវបានអនុវត្តដើម្បីសម្រេចនូវសហឧក្រិដ្ឋកម្មរួម*"[34]។

៣៧. មេធាវីការពារក្តីបានដឹងជាមុនអំពីការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចេញម្តងបន្តិចៗនូវភស្តុតាងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី ១ និងទី ២ និងទីកន្លែងកាប់សម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ទៅក្នុងសហឧក្រិដ្ឋកម្មរួមទាំងមូលនិងគ្មានកំណត់។ មេធាវីការពារក្តីក៏បានរំលឹកផងដែរថា "*ចៅក្រមត្រូវវិភាគជាពីរដំណាក់កាល ទីមួយ ត្រូវកំណត់ថា តើលក្ខខណ្ឌធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបំពេញដែរឬទេ។ ទីពីរ ត្រូវកំណត់ថាតើទម្រង់នៃការទទួលខុសត្រូវអាចត្រូវបានទទួលយកដែរឬទេ។ ការវិភាគអំពីធាតុផ្សំអត្តនោម័តិនឹងមិនអាចលាយឡំជាមួយការវិភាគទម្រង់នៃការទទួលខុសត្រូវនោះទេ* "[35]។ ត្រង់ចំណុចនេះ មេធាវីការពារក្តីបានយោងលើទឡ្ហីករណ៍នានាដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្លួនពាក់ព័ន្ធនឹង "ច្បាប់ដែលត្រូវអនុវត្ត"[36]។

៣៨. ពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សហព្រះរាជអាជ្ញាបានអះអាងថា សក្ខីកម្មជាលាយលក្ខណ៍អក្សរទាំងនេះអាចឲ្យគេបង្ហាញអំពី "*អត្ថិភាពនៃការវាយប្រហារដែលមានលក្ខណៈជាទូទៅមួយប្រឆាំងនឹងប្រជាជនស៊ីវិល ថាជាលក្ខខណ្ឌជាទូទៅមួយដែលត្រូវបំពេញ*

[34] ដូចយោងខាងលើ។

[35] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ **E163/5/9** ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ២១។

[36] ដូចយោងខាងលើ, ឯកសារ **E163/5/9** កថាខណ្ឌ ៥ ដល់កថាខណ្ឌ ២១។

*ដើម្បីឲ្យអំពើដែលត្រូវបានចោទប្រកាន់ ត្រូវបានគេចាត់ថ្នាក់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*[37] ។

៣៩. សំណើសុំរបស់ព្រះរាជអាជ្ញាបានបង្ហាញអំពីចេតនារបស់ខ្លួនជាលើកដំបូងក្នុងការប្រើប្រាស់អត្ថិភាពនៃគោលនយោបាយទាំងប្រាំធ្វើជាមូលដ្ឋានក្នុងការបង្ហាញអំពីលក្ខណៈជាប្រព័ន្ធ ឬជាទូទៅនៃការវាយប្រហារ ដែលក្នុងអំឡុងនោះមានការជម្លៀសប្រជាជន ដំណាក់កាលទី ១ និងទី ២ និងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិជ្រៃ។ នៅក្នុងសំណើសុំឲ្យមានការពិនិត្យឡើងវិញលើដីកាបំបែកសំណុំរឿង សហព្រះរាជអាជ្ញាបានបញ្ជាក់យ៉ាងច្បាស់ថា *"ប្រសិនណាជាដីកាបំបែកសំណុំរឿងត្រូវបានគេរក្សាទុក ការជំនុំជម្រះក្តីនឹងធ្វើឡើងតែទៅលើអំពើឧក្រិដ្ឋទាំងឡាយដែលស្ថិតនៅក្នុងគោលនយោបាយតែមួយគត់ ក្នុងចំណោមគោលនយោបាយទាំងប្រាំធំៗដែលបង្កើតឲ្យមានជាសហឧក្រិដ្ឋកម្មរួម ដែលត្រូវចោទប្រកាន់លើជនជាប់ចោទ។ ជាមួយគ្នានេះដែរ រាល់ទង្វើឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្នុងក្របខណ្ឌនៃគោលនយោបាយធំៗដទៃទៀត ដែលបង្កើតឲ្យមានជាសហឧក្រិដ្ឋកម្មរួម នឹងមិនត្រូវបានគេយកមកជំនុំជម្រះឡើយ ហើយដែលទង្វើឧក្រិដ្ឋកម្មទាំងនោះមាន ១). ការបង្កើត និងការគ្រប់គ្រងសហករណ៍ ការដ្ឋាន។ ២). ការអប់រំ "សមាសភាពមិនល្អ" និងការកម្ទេច "ខ្មាំង" ទាំងខ្មាំងបង្កប់ក្នុងជួរបក្ស ទាំងខ្មាំងពីខាងក្រៅ។ ៣). ការចាត់វិធានការណ៍ពិសេសមកលើក្រុមមនុស្សជាក់លាក់ ជាពិសេស ជនជាតិចាម ជនជាតិវៀតណាម និងពុទ្ធសាសនិកជន និង ៤). ការគ្រប់គ្រងលើអាពាហ៍ពិពាហ៍។ នៅក្នុងករណីនេះ វាមិនប្រាកដទេដែលថា អ.វ.ត.ក ធ្វើការជំនុំជម្រះលើទង្វើឧក្រិដ្ឋកម្មដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេបំផុត ដែលត្រូវបានប្រព្រឹត្តក្នុងក្របខណ្ឌស៊ីជម្រៅនៃផែនការរួមរបស់ជនជាប់ចោទ ដើម្បីសម្រេចឲ្យបាននូវបដិវត្តន៍សង្គមនិយមមួយនៅកម្ពុជាយ៉ាងឆាប់រហ័សតាមគ្រប់មធ្យោបាយចាំបាច់នានា ក្នុងជំហានមហាលោតផ្លោះ មហាអស្ចារ្យ និងដើម្បីការពារបក្សអំពីសត្រូវពីខាងក្នុង និងពីខាងក្រៅ"* [38]។ ការផ្លាស់ប្តូរជំហររបស់សហព្រះរាជអាជ្ញា មានកម្មវត្ថុតែមួយគត់ ក្នុងពេលបច្ចុប្បន្ននេះ គឺលាត

[37] ដូចយោងខាងលើ, ឯកសារ **E96/8** កថាខណ្ឌ ១២។

[38] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីល័ក្ខខ័ណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ*នៃវិធានផ្ទៃក្នុង ឯកសារ E124/2 កថាខណ្ឌ ៣០។

សន្និងយ៉ាងបំពាននូវវិសាលភាពនៃសំណុំរឿង ០០២/០១។ ចំណុចនេះមិនអាចទទួលយកបានឡើយ។

៤០. ដើម្បីឲ្យគោលនយោបាយដទៃទៀត ដូចមានរៀបរាប់នៅក្នុងឧបសម្ពន្ធពី ១០ ដល់ ១៦ របស់សហព្រះរាជអាជ្ញា មានលក្ខណៈសមស្របដល់ការកំណត់នូវធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដែលជាកម្មវត្ថុនៃសំណុំរឿងទីមួយ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញអំពីចំណងពាក់ព័ន្ធដោយផ្ទាល់រវាងឧក្រិដ្ឋកម្មទាំងឡាយៗខុសគ្នា ដោយបង្ហាញថាឧក្រិដ្ឋកម្មទាំងនោះ បានកើតឡើងក្នុងពេលដំណាលគ្នានិងការវាយប្រហារតែមួយ ហើយថា ប្រជាជនស៊ីវិលដែលទទួលរងការវាយប្រហារនោះគឺមានលក្ខណៈដូចគ្នា។ ដោយឡែក សហព្រះរាជអាជ្ញាពុំបានបំពេញនូវភារកិច្ចធ្វើការបង្ហាញដូច្នោះឡើយ។

៤១. នៅពេលដែលពុំមានការវាយប្រហារជាលក្ខណៈទូទៅ ឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល ឧក្រិដ្ឋកម្មនេះមិនអាចត្រូវបានគេចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានឡើយ។ ដូចគ្នានេះផងដែរ ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី "*បទបញ្ញត្តិបានកំណត់ថា ទង្វើនៃការផ្តោតមុខសញ្ញាទៅលើក្រុមមនុស្សណាមួយ ឧទាហរណ៍ ប្រជាជនស៊ីវិល ទង្វើនៃការសម្លាប់អ្នកដែលមាននិន្នាការនយោបាយប្រឆាំង ទង្វើទាំងនោះមិនអាចបំពេញលក្ខខណ្ឌនៃការអនុវត្តមាត្រា ៥ នៃលក្ខន្តិកៈ[ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ឡើយ* "។ នៅក្នុងរឿងក្តីនេះ យុត្តិសាស្ត្របានពុំបានធ្វើការកំណត់បទល្មើស "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ឡើយ ប៉ុន្តែបានលើកឡើងតែអំពីការចោទប្រកាន់លើបទឧក្រិដ្ឋកម្មសង្គ្រាមទៅវិញ[39]។

## ង. <u>**សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យមានការដាក់បញ្ចូលនៅក្នុងកិច្ចពិភាក្សានូវសក្ខីកម្មជាលាយលក្ខណ៍អក្សរ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់**</u>

[39] *វគ្គអាជ្ញា ទល់នឹង* *Fatmir LIMAJ, Haradin BALA, Isak MUSLIU* សាលក្រម លេខ IT-03-66-T ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ កថាខណ្ឌ ១៨៧។

៤២. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមានការទទួលយកបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរាប់រយពាក្យបណ្តឹង ទុកជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង។

៤៣. ឯកសារសក្ខីកម្មទាំងនោះមួយភាគធំ៖ ១). ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១។ ២). ជាប់ពាក់ព័ន្ធនឹងទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ឬ ៣). មានគោលដៅបង្ហាញ នូវធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ផ្អែកលើអំណះអំណាងខាងលើនេះ មេធាវីការពារក្តីសូមធ្វើការប្រឆាំងទៅនឹងអង្គហេតុដែលថា សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលស្ថិតនៅក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទទាំងបីនេះ ត្រូវបានគេដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សានោះ។

៤៤. ឯកសារដកស្រង់សក្ខីកម្មនីមួយៗដែលសហមេធាវីការពារក្តីលោក ខៀវ សំផន យល់ឃើញថា ជាការចាំបាច់ដែលត្រូវតែជំទាស់ទៅនឹងឯកសារទាំងនោះ ត្រូវបានបង្ហាញនៅក្នុងឧបសម្ពន្ធសមស្របដែលភ្ជាប់ជាមួយនឹងសេចក្តីជំទាស់នេះ។

៤៥. **ហេតុដូច្នេះ** មេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- **បញ្ជាក់សាជាថ្មី** ថា សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទ មិនអាចទទួលយកជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់បានឡើយ។

- **ប្រកាស** និង **សម្រេច** ថា សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងរចនាសម្ពន្ធចេញសេចក្តីសម្រេចរបស់កម្ពុជាប្រជាធិបតេយ្យ និងរចនាសម្ពន្ធគ្រប់គ្រងរដ្ឋបាលមូលដ្ឋានពាក់ព័ន្ធ និងទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ហេតុដូច្នេះមិនអាចទទួលយកបានឡើយ។

- **ប្រកាស** និង **សម្រេច** ថា សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សីដែលពាក់ព័ន្ធនឹងអង្គហេតុដែលជំទាស់ដោយមេធាវីការពារ ហើយដែលមិនត្រូវបានពិភាក្សាដេញដោលចំពោះមុខដោយអង្គជំនុំជម្រះ មានលក្ខណៈមិនអាចទទួលយកបាន។

- **ប្រកាស** និង **សម្រេច** ថា សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សីដែលពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រ និងមូលហេតុដែលនាំករកើតរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមានឯកសារដកស្រង់ពាក់ព័ន្ធនឹងទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទ មានលក្ខណៈមិនអាចទទួលយកបាន ដោយហេតុពុំមានការចង្អុលបង្ហាញណាមួយពីសំណាក់សហព្រះរាជអាជ្ញា ទៅលើផ្នែកនានានៃសក្ខីកម្មដែលសហព្រះរាជអាជ្ញាមានបំណងប្រើប្រាស់។

- **ប្រកាស** និង **សម្រេច** ថា សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងរចនាសម្ពន្ធរដ្ឋបាល និងវិធីសាស្ត្រនៃការប្រាស្រ័យទាក់ទង (ឧបសម្ព័ន្ធ ៤ ដល់ ៧) មានគោលដៅបង្ហាញអំពីធាតុផ្សំនៃបែបផែននៃការចូលរួម ដែលតាមរយៈនោះ សហព្រះរាជអាជ្ញាមានបំណងបង្ហាញអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ហើយសក្ខីកម្មទាំងនោះពាក់ព័ន្ធនឹងទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។

- **ប្រកាស** និង **សម្រេច** ថា សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមាននៅបញ្ជីនៃឧបសម្ព័ន្ធ ៨ និង ១០ ដល់ ១៦ របស់សហព្រះរាជអាជ្ញា ស្ថិតនៅក្រៅវិសាលភាពនៃរឿងក្តីដែលប្តឹងមកអង្គជំនុំជម្រះ ហេតុដូច្នេះមានលក្ខណៈមិនអាចទទួលយកបាន។

- **ប្រកាស** និង **សម្រេច** ថា សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានក្នុងបញ្ជីនៃឧបសម្ព័ន្ធរបស់សំណើសុំនេះ មានលក្ខណៈមិនអាចទទួលយកបាន។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |